
អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C


ផ្ទះសំបុក

អ្នកនិពន្ធ៖ លី ហាន់ណាហ្ស៊ី
រូបភាពដោយ៖ សែម វ៉ាស៊ីន






នៅតាមផ្លូវរ៉ាយុទ្ធបានជួបនឹងមិត្តរួមថ្នាក់ម្នាក់ឈ្មោះ សំណាង។







សំណាងបានបោះសំរាមចោលតាមផ្លូវពេលដែលគាត់កំពុង
ធ្វើដំណើរទៅសាលារៀនជាមួយឪពុកគាត់។






រ៉ាយុទ្ធបានឃើញបែបហ្នឹង ហើយក៏រើសសំរាមនោះ ដើម្បីបោះចោលនៅសាលារៀន ព្រោះតាមផ្លូវគ្មានធុងសំរាមទេ។ ជារៀងរាល់ព្រឹក រ៉ាយុទ្ធតែងតែរើសសំរាមតាមដងផ្លូវបានយ៉ាងច្រើន ទម្រាំគាត់ដើរទៅដល់ថ្នាក់រៀន។ ដៃរបស់គាត់កាន់សុទ្ធតែសំរាម។

ក.១២៣



ពេលរ៉ាយុទ្ធទៅដល់សាលារៀន មិត្តរបស់គាត់តែងតែសើចចំអកឱ្យគាត់
ហើយហៅគាត់ថា ក្មេងសំរាម។
រ៉ាយុទ្ធមិនសប្បាយចិត្តហើយថែមទាំងយំទៀតផង។





ថ្ងៃមួយ អ្នកគ្រូបង្រៀនក្មេងៗទាំងអស់ពីមេរៀនមួយដែលនិយាយពីផលប៉ះពាល់
របស់សំរាមនិងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។


សំណល់ផ្ទះបាយ


សំណល់ប្លាស្ទិក


សំណល់គ្រោះថ្នាក់






អ្នកគ្រូបាននិយាយប្រាប់កុមារទាំងអស់គ្នាថា
ការចោលសំរាមតាមដងផ្លូវផ្តេសផ្តាសធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន
ខ្យល់មានជាតិពុល បំពុលទឹកនិងដីគ្មានជីជាតិ។












អ្នកគ្រូសួរក្មេងៗ «តើកូនៗចូលចិត្តសំរាមដែរឬទេ? តើកូនៗចង់ឃើញសំរាមនៅពាសពេញដីក្នុងទឹកដែរឬទេ?» សំណាងបានឆ្លើយ «បាទ អ្នកគ្រូ! ខ្ញុំមិនចូលចិត្តទេ ហើយក៏មិនចង់ឃើញសំរាមមាននៅគ្រប់ទីកន្លែងដែរ»។ អ្នកគ្រូសួរបន្ត «នៅពេលដែលកូនៗបានឃើញសំរាមតាមដងផ្លូវ តើកូនៗគួរធ្វើដូចម្តេច?» សំណាងបានឆ្លើយ «ពួកយើងត្រូវតែរើសវាចោលក្នុងធុងសំរាម»។


រៀនគឺលេង លេងគឺរៀន














និយាយរួចសំណាងក៏បានមើលទៅមុខវ៉ាយុទ្ធហាក់បីដូចជាដឹងខ្លួនខុសថា
មិនគួរនិយាយបង្អាប់មិត្តបែបហ្នឹងនោះទេ។





ពេលចេញលេង សំណាងក៏បាននិយាយទៅកាន់រ៉ាយុទ្ធ «រ៉ាយុទ្ធហ៊ាន
ឱ្យខ្ញុំសុំទោសណាដែលនិយាយមិនល្អដាក់ឯង»។





រ៉ាយុទ្ធក៏មិនបានខឹងនឹងសំណាងដែរ។ ពួកគេតែងតែលេងជាមួយគ្នាយ៉ាងសប្បាយរីករាយ
នៅសាលារៀន។





មិនយូរប៉ុន្មាន តាមផ្លូវទៅសាលារៀនមិនឃើញមានសំរាមដូចមុនទៀតទេ។
រ៉ាយុទ្ធសប្បាយចិត្តវិញហើយ។





ក្មេងសំរាម

គំនូរជីវចល

អ្នកនិពន្ធ៖ លី ហាន់ណាហ្វី

ធនធានបង្រៀន

រូបភាពដោយ៖ សែម រ៉ាស៊ីន

រ៉ាយុទ្ធជាក្មេងរស់នៅទីជនបទ។
គាត់ជាកុមារាម្នាក់ដែលមានសណ្ដាប់ធ្នាប់និងអនាម័យល្អ
ហើយគាត់តែងតែជួយការងារផ្ទះម្ដាយគាត់ជារៀងរាល់ថ្ងៃ។

(ហូតចេញត្រឹមខ្សែបន្ទាត់)

រ៉ាយុទ្ធតែងតែដើរទៅសាលារៀនជារៀងរាល់ព្រឹក។

(ហូតចេញឱ្យឃើញរូបភាពពេញ១ទំព័រ)

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary